— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៨៩ ជីឡូត៍លេខ ២៩៤ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ ២៥ រ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៤១

ប៉ាយជីតាយពោលហើយ, យាវជើងឆ្វេងថ្លក់ជើងនាយ ៗ ស៊ុំផធានគ្រាន់តែទ្រេតទ្រោតបន្តិច ក៏គេចផុតយ៉ាងឆាយ ពុំបណ្តាយឲ្យគាត់គាវជើងផ្លូលផ្ដាប់មុខឡើយ ។

ស្មៀតពាប់ខ្ញុំ, តាប់ប្យាម និងយាវជើងថ្លក់ទាំងបីនេះធ្លាប់ធ្វើឲ្យអ្នកក្លាហានជាច្រើនចុះញ៉ម ៗ តែម្ដងនេះទោះស្មៀតទាំងបី បានសំដែងចប់ចុងចប់ដើមយ៉ាងត្រឹមត្រូវបែបណាក៏ដោយ ក៏ហាក់គ្មានប្រសិទ្ធភាពសោះ ព្រោះមិនអាចបង្ក្រាបមាណពដែលមានកម្លាំងជាគុជ៏ស្ដុកស្តម្ភបាន ។

ថ្ងៃមុន ប៉ាយជីតាយជួបបងប្អូនត្រកូលទីងទាំងបី ហើយព្រួទីងមិនហួសប្អូនប្រាប់ថា យាយស៊ុំបានទៅស្នាក់នៅក្នុងខ្សែងខៀវជាមួយខ្លួន ជាហេតុធ្វើឲ្យគាត់ខឹងក្រោធ និងប្រណែនប្រចណ្ឌទាល់តែវង្វេងស្មុង ។ ថ្ងៃនេះបានឃើញប្រពន្ធសម្លាញ់ត្រឡប់មកវិញ គាត់ដឹងថាទីងមិនហួសប្អូនប្រឌិតរឿងបោកប្រាសគាត់ទាំងស្រុង ក៏រកកាយឡើងវិញ ហើយគួរស្បើយពីកុគន្លួតខ្វះដៃរ ៗ តែនៅមានគំនិតមួយដែលនិយមថា គាត់មានវិជ្ជាពូកែលើសលុបក្នុងលោក ។

គាត់ចាស់វ័យមាណពបីស្មៀតឥតបានលទ្ធផលបន្តិចសោះ ក៏

ទំនេះគួរសរសើរសតិលើសដើម លើកដៃទះរូតាំងកំភេលតម្រង់ទ្រូងស៊ុំផានជាលើកចុងក្រោយ ។

ស៊ុំផានលាន់ខ្យល់ម្ដងនេះខ្លាំងក្លាហើយសាហាវជាងមុន ក៏លើកដៃឆ្វេងរេកាត់យ៉ាងប្រញាប់ ។ ប៉ាយដឹតាយយារដៃឆ្វេងដាល់ជួនវិញ, មាណពគេចមិនទាន់ទទួលមួយដៃត្រូវស្មាទ្រូងតបន្តិច ។ អាស៊ីវស្រែកយ៉ៃ ! ស៊ុំផានឆ្លៀតពេលស្រែកប្រាប់នាងថា :

- កុំភ័យ, ខ្ញុំឥតឈឺទេ ។

ប៉ាយដឹតាយស្រែកគំហក:

- យើអាប្រមក់ ! បើមិនឈឺចាំយើងថែមឲ្យមួយដៃ ។

ពោលចប់យារដៃដាល់មាណពម្ដងទៀតមែន, តែលើកនេះស៊ុំផានគេចទាន់ ។

អាស៊ីវឈរមើលយូរឡើងកាន់តែឃើញអ្នកទាំងពីរថ្មឹកដៃថ្មឹកជើង បញ្ចេញកាយវិការរឹតតែរហ័សឡើង ។ ប៉ាយដឹតាយវាយមាណពក្ដុំផប់ស្ទៀតប្រហែលត្រូវប្រាំពីរឬប្រាំបីទៅហើយ, នាងភ័យណាស់ចេះតែស្រែករំពុកដីតា:

- លោកតាអាណិតគាត់ផង !

តែលុះឃើញស៊ុំផានមានទឹកមុខធម្មតាហាក់ឥតឈឺបន្តិចសោះ នាងក៏អន់ភ័យ ។ ចំណែកប៉ាយដឹតាយមុនដំបូងនៅចាំបណ្ដាំយាយស៊ុំ, គាត់បញ្ចេញកម្លាំងតែចំបួនភាគប៉ុណ្ណោះ វាយត្រូវមាណពប្រហែលដប់ប្ដូដៃចេះតែបារម្ភខ្លាចនាយមានរបួស ។ លុះឃើញស៊ុំផានទ្រាំទ្រមានចូលប្រយុទ្ធទៅទៀតរឹតតែរហ័ស, រឹតតែខ្លាំងគាត់ក៏យល់ថ្លុក ១ ហើយទឹងក្រោធបន្ថែមកម្លាំងបន្តិចម្ដងៗ ៗ ចំឡែកមែនទែន, តាចាស់បើកភ្នែកគ្រលួនមើលស៊ុំផាន ដែលគ្រាន់តែទ្រេតបន្តិច ឈរត្រង់ខ្លួនដូចដើមចូលប្រយុទ្ធធ្វើព្រងើយ !

តាចាស់ស្រែកគ្រហឹមបន្ថែមកម្លាំងក្នុងការវាយលុក, ទះតប់ម្ដងៗ ខ្យល់ដៃគាត់បោកបក់ខ្សែប្រវាត់ប៉ះសសរកណ្ដាលតុក៉េកក៉ក ១ ... អាស៊ីវថយទៅឈរអែបជញ្ជាំងហើយ ក៏នៅចង់ចប់ដង្ហើបដែរ ១ នាងទ្រាំមិនបានក៏ប្រានទ្វារដើរចេញទៅ ។ មកដល់ខាងក្រៅនាងឈរមើលលោកតាដាល់ទះតប់ស៊ុំផានកាន់តែញាប់ឡើងសាហាវឡើង នាងក្រុំភ័យណាស់, ឈឺជំនួសស៊ុំផានតាលតែមិនហ៊ានមើលស្ទុះទៅតាញទ្វារបិទជិត ។

នាងក្រមុំឈរខាងក្រៅចង់ស្រែកសុំឲ្យធាកប្រយុទ្ធនេះធាប់ចប់ទៅ, ឲ្យស៊ុំផានសុខសប្បាយ,

កុំឲ្យមាននរណាចាញ់នរណាឈ្នះ នាំនាងលំបាកចិត្ត ។

ពេលនោះទ្វារដែលនាងផ្អែករង្គើតិចៗ ដោយសារកម្លាំងខ្យល់ដៃតាចាស់និងមាណពបោកបក់មក ឯប្រវាត់ចេះតែគេប៉ះសសរ ព្រ ខ្ទាំងឡើងៗ ។ នាងក្រមុំញាប់ញ័របេះដូងនឹកមុខ លែងចង់ស្ដាប់ លែងចង់មើលអ្វីទៀត, នាងទទួលអារម្មណ៍ហាក់ដូចផែនដីវិលខ្វាល់ចង់ក្រឡាប់ រួចនាងទន់ត្របកភ្នែកលែងដឹងខ្លួន . . .

កន្លងមកមិនដឹងប៉ុន្មានម៉ោង, អាស៊ីវភ្ញាក់ព្រើតផ្ទៀងត្រចៀកស្ដាប់លែងឮស្នូរខ្យល់, លែងឮប្រវាត់បោកប៉ះសសរនិងទ្វារ ហើយក្នុងបន្ទប់ដូចជាស្ងាត់ស្ងៀមឈឹង ! នាងចាំផ្ទៀងស្ដាប់មួយសន្ទុះទៀតមិនឮសូរស័ព្ទអ្វីសោះក៏កើតតែភ័យរន្ធត់នឹកថា:

– លោកតាឈ្នះឬ«គាត់»ឈ្នះ ? លោកតាវាយគាត់របួសឬគាត់វាយលោកតា ? អេ . . . បើលោកតាឈ្នះ ច្បាស់ជាយើងឮសំណើចក្អាកក្អាយខ្លាំងត្រចៀកហើយ ! ប្រសិនបើ «គាត់» ឈ្នះវិញ, គាត់ត្រូវប្រានទ្វារចេញមកក្រៅប្រាប់យើង ។ យីម៉េចក៏គ្មានឮអ្វីដូច្នេះសោះ ? ឬមួយ... ឬមួយគាត់របួសទាំងអស់គ្នា កំរើកលែងរួច ? ឱ ! លោកអើយ, ជួយផង !

នាងក្រមុំក្រោកទាំងញ័រទទ្រើកប្រានទ្វារថ្នមសន្សឹមៗនាងធ្មេចភ្នែកទាំងពីរពុំហ៊ានមើលស្ថានការណ៍ក្នុងបន្ទប់ទេ ខ្លាចឃើញពីការដ្ឋានខ្លោចផ្សាបែបណា ឬឃើញសាកសពមួយជាជំនួសមនុស្ស ។ អស់ពេលដ៏យូរទើបនាងប្រមូលកម្លាំងស្មារតីបើកភ្នែកព្រិមៗឃើញប៉ាយដីចាយនិងស៊ីផាន អង្គុយផ្ទាល់ដី, តាចាស់ធ្មេចភ្នែកជិតឈឹង, មាណពក្រឡេកមើលនាងក្រមុំដោយញញឹមយ៉ាងស្រស់ ។

អាស៊ីវលាន់មាត់ហើយដកដង្ហើមយូរកំចាត់ទុក្ខព្រួយ ។ បន្ទាប់មកនាងបើកភ្នែកធំពិនិត្យមែនទែន ឃើញស៊ីផានដាក់ដៃលើខ្នងជីតានាង គឺមាណពកំពុងជួយបញ្ជូនកម្លាំងធាតុទៅឲ្យលោកតា ។ នាងសួរថា:

– លោកតា... បានរបួសឬ ?

ស៊ីផានតប :

– គ្រាន់តែស្ទះដង្ហើម, បន្តិចទៀតបានស្រួលវិញហើយ ។

ភ្លាមនោះប៉ាយដីចាយស្ទុះក្រោកក្អកតំហក :

– ស្ទះដង្ហើមយ៉ាងម៉េចអាប្រមក់ ? ពេលនេះយើង, យើងស្រួលខ្លួនទេតើ !

ពោលស្ទើរមិនទាន់ផុត តាចាស់យារវៃទះក្បាលមាណពភ្លាម ។ ប៉ុន្តែគាត់ក្វាក់ក្រញាំងដក ដៃមកវិញសម្លឹងមើលបាតដៃទាំងពីរដែលហើមស្គរប៉ោងប៉ង់ប្រេះហើយឡើងពណ៌ក្រហមទុំចង់ស្វាយ ។ បើហ៊ានទះក្បាលមាណពមែន, ដៃទាំងពីរនោះពិតជាបែកធ្លាយចេញឈាមមិនខាន ។

តាចាស់ស្រឡាំងកាំងមួយស្របក់ទើបនឹកឃើញ ។ ព្រោះស៊ីផានមានកម្លាំងជាគុណច្រើន ជាអតិបរមា គាត់វាយតប់ត្រូវខ្លួនប្រាណនាយគ្រប់កន្លែងមិនអាចបណ្ដាលឲ្យអ្នកកម្ទោះឈឺ ឬរបួសឡើយ, វាប្រទាំងតបតាចាស់វិញដូចគាត់វាយផ្ទាំងថ្ម ទាល់តែហើមដៃឈឺព្រាំមិនបាននេះឯង ។ បន្ទាប់ពីនោះតាចាស់ទទួលអារម្មណ៍ ឈឺស្ពឹកជើងទៀប ៗ ដូចមានម្ជុលរាប់រយពាន់ចាក់ឈឹប ៗ ... ប៉ាយជីតាយនឹកឃើញគាត់ទាត់ធាក់មាណពត្រូវប៉ុន្មានជើងនោះ ក៏ឈរស្រឡាំងកាំងដកដង្ហើមយូរៗ ហាក់ដូចចង់ជម្រុះការតានតឹងក្នុងចិត្ត ។ តាចាស់អស់សង្ឃឹម នឹកថាសំដីអួតក្អេងក្អាងទាំងប៉ុន្មានប្រែក្លាយជាឥតន័យ, ជាសំដីបោកប្រាសខ្លួនឯងទៀត ! គួរខ្មាសគេមែន !

ប៉ាយជីតាយទឹងចិត្តផងស្ដាយក្រោយផង ស្ទុះស្ទារើសខ្នោះដែកមកពាក់នៅដៃ-ជើងវិញ ហើយទាប់ទាញគន្លឹះដាក់ខ្លួនឯងឮគ្រឹប ១ ៗ បន្ទាប់មកទៀតគាត់រើសកូនសោខ្នោះគ្រវាត់គ្រវែងលើជញ្ជាំងថ្មទាល់តែវៀចវេរអស់ ។ អាស៊ីវឃើញដូច្នេះភ័យណាស់ស្រែកសួរ:

- លោកតា . . លោកតាយ៉ាងម៉េចហើយ ?

ប៉ាយជីតាយងាកមុខទៅកៀនជញ្ជាំងហុចខ្នងឲ្យចៅស្រីហើយពោលថា :

- ប៉ាយជីតាយយើងនេះមានកំហុសធ្ងន់ណាស់ត្រូវលន់តួទោសដោយបែរមុខទៅរកជញ្ជាំងរហូតដល់ពេលគាត់ពុក ។ ឯងនាំគ្នាចេញទៅក្រៅចុះកាលែងត្រូវការជួបនរណាហើយណា ! ចៅស្រីទៅប្រាប់ជីដូនឯងផងថា ទៅក្នុងខ្យង់ទៀវមិនបាច់ត្រឡប់មកវិញទេ ។

អាស៊ីវនិងស៊ីផានមើលមុខគ្នាឡេងឡង់មិនដឹងហាមាត់អង្វរតាចាស់ថាម៉េច ។ មួយសន្ទុះទើបអាស៊ីវបន្ទោសស៊ីផាន:

- មកពីបងឯងហ្នឹង ! ម៉េចបង់ឈ្លះម្ល៉េះ ?

ស៊ីផានស្រឡាំងកាំង:

- បង... ឥតទេ ! បងគ្មានវាយត្រូវជីតាអូនមួយដៃសោះ ។

អាស៊ីវសម្លុត :

- គាត់ជាជីតាខ្ញុំម្នាក់ឯងឬ ! បងគ្រាន់តែហៅលោកតាមួយម៉ាត់ដែរមិនបាន, ខ្លាចថោកទាបឬ ?

ស៊ីផានក្រេវក្រោធក្រៃលែង ពោលតិចៗ :

- លោកតា !

ប៉ាយឌីតាយកដៃពោលតបថា :

- ទៅចុះៗ, ឯងពូកែជាងយើង...យើងជាចៅរបស់ឯង , ឯងជាជីតាយើង !

ស៊ីផានលៀនអណ្តាត :

- ហ៊ឺ ! អស្ចារ្យណាស់កាស៊ីរ, អ្នកណាក៏ដោយ, ឲ្យតែឃើញខ្ញុំសុទ្ធតែថា ខ្ញុំជាស៊ីផុនយី សូម្បីម្ចាស់ភូមិនិងលោកស្រីក៏ប្រឡំដែរ, ម៉េចមានតែអូនម្នាក់ដែលមិនប្រឡំនឹងគេ ?

អ្នកទាំងពីរចេញពីបន្ទប់ថ្មកដល់ផ្លូវខាងក្រៅកំពុងដើរកាត់សួនច្បារ ៗ កាស៊ីរមាណព សួរបែបនេះក៏ឈប់ឈឹង .. ញ័រខ្លួនប្រែមុខសស្លាំង ៗ នាងលូកដៃកាន់មែកម៉ុះមុខនាង ពណ៌សក្បុសស្ងួចផ្អាម្ចុះ នាងពោលតិច ៗ:

- កាលមុនស៊ីផុនយីនោះបង់ធ្វើបាបខ្ញុំទាល់តែខ្ញុំខឹងរកលោកតាក្នុងជ្រោះសម្លាប់ខ្លួន ៗ បងអា ! តើបងអាចសម្លាប់គាត់នោះសងសឹកឲ្យខ្ញុំទេ !

មាណពទីទើរពន្យល់នាងថា :

- គេជាកូនប្រុសតែមួយគត់របស់លោកម្ចាស់ភូមិស៊ីនិងលោកស្រី ដែលរាប់អានស្រឡាញ់បងណាស់, កាស៊ីរ,បង . . . បងលើកដៃសម្លាប់កូនគាត់មិនកើតទេ ៗ

កាស៊ីរល្ហោកមុខបណ្តោយឲ្យទឹកភ្នែកហូរជោកជាំ ៗ នាងពោលទាំងខ្សឹកខ្សួល:

- នេះជាលើកដំបូងដែលខ្ញុំពឹងបង បងមិនព្រមធ្វើតាមទៅហើយ,ចុះដល់ថ្ងៃក្រោយយ៉ាងម៉េចទៅ ? បងច្បាស់ជាធ្វើបាបខ្ញុំដូច ... លោកតាធ្វើបាបលោកយាយអ៊ីចឹង ៗ ខ្ញុំ . . . ខ្ញុំទៅដូចលោកយាយហើយ !

ពោលចប់នាងរត់ទៅ ស៊ីផានស្រែកឃាត់ :

- កាស៊ីរ, កាស៊ីរចាំស្តាប់បងសិន !

កាស៊ីរខ្ទប់មុខស្រែកតប :

- បើបងមិនទៅសម្លាប់គេឲ្យខ្ញុំ, ខ្ញុំឈប់រវល់នឹងបងទៀតហើយ !

នាងក្រមុំរត់ទៅមុខដល់បន្ទប់ខាងក្រៅ ។ ស៊ីផានរត់តាមក្រោយដល់មាត់ទ្វារបន្ទប់ ក៏ឃើញពន្លឺដាវផ្លេក ១ គឺមនុស្សបួននាក់កំពុងប្រយុទ្ធគ្នាយ៉ាងសាហាវ ។ នាយស្គាល់ជាក់ជាប៉ាយរ៉ាន់ដាន, ឈិងជីសេ, ឈីជីមានកាន់ដាវក្លីផ្លេកឡោមព័ទ្ធតាចាស់ម្នាក់ពុកមាត់ខ្វាត់ពាក់អាវខៀវ ។

មាណពស្រែកខ្លាំងៗ :

- លោកអ៊ំសុខសប្បាយទេឬ ? យើងខានជួបគ្នាយូរហើយ ។

តាចាស់អាវខៀវគ្មាននរណាក្រៅពីសៀយានទីម្ចាស់ភ្នំម៉ានទេ ។ គាត់កំពុងមានប្រៀបលើសិស្សក្មេងៗកកកុញតាំងបីបញ្ជាក់ថាគាត់ខ្លាំងពូកែណាស់ ។ ដល់ឮសម្រែកស៊ីផាន គាត់ងាកភ្លេតទៅមើលហើយក្រាក់ក្រើតស្រែកក្លាក់សម្លេង :

- អ៊ឺ ? ម៉េចមានមួយទៀតហើយ ?

ដោយសារការភ្លេសប្រហែសបន្តិចនេះ សត្រូវតាំងបីក៏ឆ្លៀតពេលសំរុកដាវរំលេចចុងមកកក្បាលពោះគាត់ព្រមគ្នា ។ អ្នកតាំងបីរៀនពីគ្រូតែមួយ, គុនដាវតែមួយ, កាលបើឆ្លៀតដាវមួយដូចគ្នាក្លួសត្រូវគេបមិនផុតពីមរណៈឡើយ ។ មើលទៅសន្ទុះដាវកាចសាហាវ ឥតបេះយោគយល់នរណាទេ, បានតែចម្ពុះពោះសៀយានទីក្លាយពោះរៀនពោះតាំងមួយមុខប៉ុណ្ណោះ ។

ស៊ីផានស្រែកក្លាក់សម្លេងថា:

- ប្រយ័ត្ន !

ព្រមតាំងបង្ហើរខ្លួនចូលទៅចាប់ខ្នងប៉ាយរ៉ាន់ដានយូរផុតដី ។ ពេលជាមួយនោះឮស្ងួរផស ! ផស ! គឺក្នុងគ្រាប្រជុំបញ្ចប់, សៀយានទីបញ្ចេញយុទ្ធសិល្បៈដៃទៀតគោះដាវឈីជីបានផង, ដាវឈិងជីសេផងបាត់ដំណាលគ្នា, តែពោះគាត់រហ័សយ៉ាងណា ក៏ផ្លែដាវទាំងគូរក់ត្រូវអាវគាត់រហែកបន្តិចដែរ ។ បើកុំតែបានស៊ីផានក្រឡួចប៉ាយរ៉ាន់ដានលើកចេញទាន់ម៉េ្លះចុងដាវអ្នកក្លាហានទិសឧត្តរបាក់ចម្ពុះពោះសៀយានទីបាត់ទៅហើយ ។

សៀយានទីក្រឡប់ដៃទាំងពីរទះដាំង ១ ទាល់តែឈិងជីសេខ្ទាតដល់ជញ្ជាំងលាន់ផាំង ! ធ្លាក់កំទេចធ្លុះបីរពុយ ។ ក្នុងពេលជាមួយគ្នានោះឮ ផាំង ! គឺប៉ាយរ៉ាន់ដានទះកំភ្លៀងស៊ីផានមួយដៃអស់ទំហឹង ។

សៀយានទីសម្លឹងមុខស៊ីផានមួយសន្ទុះ រួចងាកទៅមើលស៊ីជុងយីដែលផ្ដេកផ្អែកជញ្ជាំង ។

គាត់សួរទាំងងឿងឆ្ងល់ :

— ឯង ... ឯងទាំងពីរម៉េចក៏ដូចគ្នាម្ល៉េះ ?

ស៊ីផានដាក់ប៉ាយវ៉ាន់ជានចុះវិញ ហើយបញ្ចេញទឹកមុខរីករាយ ពោលថា :

— លោកអាំងសេ, លោកអឺមកជួយខ្ញុំឬ ? ខ្ញុំសុខសប្បាយទេតើ, គ្មាននរណាសម្លាប់ខ្ញុំទេ, សុំអរគុណអីណាស់...អូខឹងៗ តុងៗ ... លោកបងស៊ុកអញ្ជើញមកជាមួយដែរ .... លោកម្ចាស់គូមិស៊ីព្រមទាំងលោកស្រីសុខសប្បាយទេហ្ន៎ ! សាធុ ! សាធុទៅលោកអើយ ! អ្នកគ្រូ, លោកតាពាក់ខ្នោះដៃខ្នោះជើងវិញហើយ , គាត់មិនព្រមចេញទៅក្រៅទេ ដែលទាំងមានប្រសាសន៍ថា ឲ្យអ្នកគ្រូអញ្ជើញទៅក្នុងខ្យងទៀតហ្នឹងផង ។

ក្នុងមួយនាទីនេះស៊ីផានពោលពាក្យគួរសមទៅកាន់មនុស្សមួយចំនួនធំ ក្នុងបន្ទប់ដែលបានទាក់ទងជាមួយនាយតាំងពីមុនដល់ពេលនេះដោយធម្មតា តែអ្នកស្តាប់ទាំងប៉ុន្មានក៏យកភ្នែកគ្រប់គ្នា នឹកឃើញប្លែក ៗ ...

ក្បែរកាលនៅក្នុំម៉ាន សៀយានខ្ទី ខំហាត់យុទ្ធសិល្បៈកម្លាំងដៃទៀតយ៉ាងខ្លាំងខ្លួន ។ ថ្ងៃមួយនោះគាត់កំពុងតែសាកល្បងវាយដើមឈើបង់ជឹងកំរិតយុទ្ធសិល្បៈផ្ទាល់ ដោយបានចំណាយកម្លាំងអស់មួយភាគធំស្រាប់តែឃើញគ្រូពេទ្យដៃដែកនាំសហការីខាងក្រុមណាមនល្បប្រាំបីរូបស្ទួនរកនាយក្រុមគេដល់ក្នុំម៉ាន ។ មិនតែប៉ុណ្ណោះគេចោទសៀយានខ្ទីថា នាយក្រុមគេពិតជានៅជាមួយគាត់លើក្នុំហ៊ីង ។ សៀយានខ្ទីប្រើកលល្បិចចាប់នាយក្រុមតន់ហ៊ុងយ៉េហើយបានប្រយុទ្ធជាមួយតៃហែស៊ុ ។

គ្រូពេទ្យដៃដែកពូកែគ្រាន់បើ,ត្រូវនឹងសៀយានខ្ទីអស់កម្លាំងស្រាប់ផង ក៏បង្អង់ដៃធ្វៀតរកឱកាសគេចខ្លួនមុនពេលចាញ់. ព្រោះសៀយានខ្ទីធ្លាប់ស្គាល់គានឹងគេដែរ គាត់មិនសុខចិត្តចុះចាញ់តៃហែស៊ុទេ ។ សៀយានខ្ទីជាអ្នកក្លាហានមួយរូបនឹងគេដែរ, បានបញ្ចេញថ្វាំងបញ្ចាក្នុងពិភពលោកបានសេចក្តីថាគាត់ការយុទ្ធសិល្បៈប្រហាំកាយណាស់ដែរ ។

ប៉ុន្តែការដែលគេចោមរោមបន្ទិះគាត់ខាងផ្លូវចិត្តឲ្យចុះចាញ់ក្នុំម៉ានជាលំនៅ. សៀយានខ្ទីចាត់ទុកជាការកេរ្តិ៍ម៉ាសមុខមួយដ៏សំខាន់រកបំភ្លេចមិនបានជាដាច់ខាត ។

គាត់ពិចារណាសព្វគ្រប់ឃើញថាមកពីគាត់សាកល្បងបង្ហិនកម្លាំងក្នុងថ្ងៃនោះឯងបើពុំនោះសោត តៃហែស៊ុពុំនាក់កប់ឈ្មោះគាត់ដែរ !

សែ៊យានទីកប់គំនុំនេះទុកក្នុងបញ្ជី ហើយស្វែងរកកន្លែងស្នាក់ហ្វឹកហ្វឺនយុទ្ធសិល្បៈផងទៀតទៅទៀត, រហូតដល់ពេលគាត់បេះស្ពាត់ហើយជឿជាក់ថាគ្មាននរណាទ្រាំទ្របានទើបសម្រេចចិត្តទៅជំរះបំណុលដល់ទីតាំងក្រុមឈានល្អនៅស្រុកយ៉ាំងចូវតែម្តង ។

គ្រាន់តែទៅដល់ភ្លាមសែ៊យានទីវាយនាយគ្រូតរបួសអស់ប្រាំមួយនាក់ធ្វើឲ្យមានការបលាបល់ជ្រួលច្របល់ពេញក្រុមឈានល្អទាំងមូល ។

ពេលនោះស៊ីផានបាញ់កលឧបាយនាំងទឹងតុង ក្លែងខ្លួនធ្វើស៊ីផុងយីទៅតាមប្តីប្រពន្ធស៊ីឈីងបាត់ហើយ ។ រីឯស៊ីផុងយីមែនទែនដើងវិលខ្ចប់លេខម្លុយនោះកំពុងតែបបួលទឹងតុងប្រុងរត់ទៅរកកន្លែងថ្មីកសាងជីវភាពតែគេចាកចេញមិនផុតពីទីតាំងនោះ ព្រោះក្រុមឈានល្អដាក់គងយាមល្បាតគ្រប់ច្រកល្ហកនាំឲ្យ « លោកនាយក្រុម » ត្រឡប់មកជំរឿញក្នុងពេលថ្មី ។

ស៊ីផុងយីតាល់ច្រកក៏ទ្រាំក្លែងធ្វើស៊ីផានបាញនាយក្រុមបណ្តោះអាសន្នសិន ។ ប៉ុន្តែវិលបំណាប់នេះមានល្បិចប្រាជ្ញា ហើយធ្លាប់ដឹងចិត្តសមាជិកក្រុមឈានល្អស្រាប់ផងក៏បេះធ្វើមិនឲ្យអ្នកណាសង្ស័យឡើយ ។ ទោះបីយ៉ាងនេះក្តីនាយមិនសូវហ៊ានចេញមកវាយឫកក្រអឺតក្រទមប្រុងក្អេងក្អាងដូចលើកមុនដែរ ។ នាយតែងសម្ងំក្នុងបន្ទប់ដោយទុកដាក់កិច្ចការទាក់ទងនឹងក្រុមបក្សឲ្យតៃហៃស៊ីតាត់ចែងជំនួស ។ នាយធ្វើបែបនេះ ក៏ល្មមតាមបំណងសម្ងាត់របស់ក្រុមឈានល្អទាំងមូលដែរព្រោះគេត្រូវការឃាត់នាយទុកទៅការពារទ្រព្យស៊ីមុជំនួសគេប៉ុណ្ណោះទេ, ទោះមិនវល់នឹងកិច្ចការផ្សេងៗ ក៏គេមិនខឹងដែរ ។

សែ៊យានទីនៅចំណាំមុខនាយគ្រូតដែលឡើងភ្នំម៉ានទាំងអស់ ម្ល៉ោះហើយក្រៅពីនីហ៊ុងយេគាត់វាយផ្តួលបាប់គិតពីនរណាទេ ។ លុះគ្រប់ប្រាំមួយនាក់ហើយគាត់ហៅតៃហៃស៊ីចេញមកភ្លាម ។ ពាននាយគ្រូតមួយរូបទៀតតៅទៅបំពេញបេសកកម្មទីណាបាត់ហើយទើបរួចខ្លួន ។

ចំណែកតៃហៃស៊ីមិនមែនល្ងង់ទេ ។ ពាំងពីនាំស៊ីផានចុះពីភ្នំម៉ានមក, គាត់ដឹងថាការបន្ទុំសែ៊យានទីឲ្យចាក់ចោលលំនៅបែបនេះមិនមែនបានសុខស្រួលទេ ។ ប៉ុន្តែគ្រូពេទ្យយល់ខុសថាសែ៊យានទីមិនសូវមានកម្លាំងកាយទើបមិនសូវព្រួយបារម្ភ ។

លុះនាំស៊ីផានមកដល់ទីតាំង, លោកគ្រូពេទ្យភ្ញាក់ខ្លួនដោយស៊ីផានមិនមែនស៊ីផុងយីសោះ ។ គាត់មានការសោកស្តាយ ដោយបានចងគំនុំនឹងសែ៊យានទី ដោយសារក្មេងម្នាក់មិនដឹងមកពី

ណា, ម៉្យាងទៀតសេនាបញ្ញាមរណៈដិតចេញមុខមកប្រតិបត្តិការទៀតហើយ ត្រូវកនាយក្រុមសំរាប់ដឹកនាំទិន្នទទួលខុសត្រូវលើសមាជិកទាំងអស់ ទើបសមហេតុសមផល ។ តៅហៃស៊ីឃើញស៊ុផឆានសន្ទប់សន្ធិនគ្មានដឹងរឿងហេតុ ដោយសារការហាត់រៀនកម្លាំងធាតុផ្ទុយគ្នានោះ លួចប្រព្រឹត្តអំពើថោកទាបខ្លះលើរូបស៊ីផឆាន ។

ត្បិតកាលមុនពួកគាត់បានញុះញង់ស៊ីផុងយីឲ្យធ្វើនាយក្រុមឈានល្អមែន, តែមិនបានប៉ុន្មានថ្ងៃផង កុម្មោះដើងខិលលួចរត់បាត់ស្រមោល ។ តៅហៃស៊ីខំស្វែងរកចាប់បានមកវិញ ចាប់សម្រាតខោអាវនាំយកទៅឃុំទុក ។ ទីបំផុតស៊ីផុងយីលបលួចរត់បាត់ទៀតធ្វើឲ្យតៅហៃស៊ីព្រួយបារម្ភណាស់, ប៉ុន្តែស្វាកស្នាមទាំងប៉ុន្មាន ដែលគាត់បានឃើញលើរូបកាយស៊ីផុងយីគាត់បង់បាំងទាំងអស់មិនអាចបកេ្ខបបានឡើយ ។

តៅហៃស៊ីជាគ្រូពេទ្យស្រាប់ក៏គាត់តែងស្វាកស្នាមលើស្នា, ក្លៅទិដ៏កំបេះគូបឲ្យស៊ីផឆានក្លាយជាស៊ីផុងយីបេះបិត ទាល់តែទីងតុងជាសង្សារ, ប៉ាយវ៉ាន់ជានជាគ្រូ,រហូតប្តីប្រពន្ធស៊ុឈីងជាឪពុកម្តាយក៏ប្រឡំដូចគ្នា ។

តៅហៃស៊ីស្មានម៉្យាងទៀតថាស៊ីផុងយីរត់រួចហើយ វាមិនល្ងង់បញ្ចេញមុខមកកេអ្វីទៀត នៅមុនពេលសន្យាជប់លៀងបបរខែកត្តិកទេ ។ ព្រោះហេតុនេះហើយបានជាតៅហៃស៊ីឥតក្រែងរអែងហ៊ានកុហកអ្នកដទៃនិងកុហកមាណពស្លូតត្រង់នាមស៊ីផឆានឲ្យក្តៅឥតព្ងួយ ។

តាមពិតស៊ីផឆាននិងស៊ីផុងយីដូចគ្នាខ្លះមែន តែមានចំណុចសំខាន់ ត្រង់ស្នាមប្ញួសម៉ឺកខ្ទង់នោះដែលធ្វើមិនឲ្យគេសង្ស័យឬរកញែកគេខុសត្រូវ ។ ស៊ីផឆានល្ងង់ខ្លៅហើយគ្មានការពិសោធក្នុងជាតជីវិតក៏ចេះតែជឿតាមគេប្រាប់ថានាយឈឹធ្វន់ក្មេងរឿងពាល់ ។ មានតែសេនាកោះឡុងមុតរូបនោះទេដែលមានឥទ្ធិពលខ្លាំងក្លា ប្រាជ្ញាវាងវៃដើរស្វែងរកបើកកាយ ទាល់តែឃើញស៊ីផុងយីមែនទែន ។

ធាកល្ហានរបស់គ្រូពេទ្យដែលធើតក៏សន្មត់ថាចប់ត្រឹមហ្នឹង, ទោះស៊ីផឆានសុខចិត្តទទួលផ្ទាកបញ្ញក្នុងឋានៈជានាយក្រុមឈានល្អដើម្បីជួយរំដោះគ្រោះបងប្អូនក្នុងក្រុម ក៏តៅហៃស៊ីនៅអៀនខ្មាសមិនសូវចេញមកជួបស៊ីផឆានញឹកញាប់ឡើយ ។ កត្តាអស់នេះជាហេតុជួយសម្រួលការកិច្ចស៊ីផុងយីកំហូចដែលក្លែងធ្វើស៊ីផឆានឥតឲ្យអ្នកណាដឹងក្រៅពីទីងតុង ។

ថ្ងៃដែលសៃហានខំទៅកាន់ក្រុមឈានល្អវ៉ាយនាយត្រួតប្រាំមួយនាក់ ហើយស្រែកហៅឈ្មោះ

ចៅហៃស៊ីឲ្យទៅជួយនោះ, គ្រូពេទ្យដែលតែងយល់ច្បាស់ណាស់ថា ទោះចេញទៅតដៃក៏មិនអាចយកឈ្នះលើម្ចាស់ក្តីបានដែរ ។ ប៉ុន្តែគាត់ត្រូវចេញទៅឃាត់ឃាំងសិនចាំប្រើគេទៅអញ្ជើញលោកនាយក្រុមចេញជួយការពារ ។

ស៊ីផុនយីម្តេចនឹងហ៊ានចេញ ? សេនាចូលទៅអញ្ជើញហើយអញ្ជើញទៀត ឈរចាំពេញបន្ទប់ព្រមទាំងជូនដំណឹងហួរហៃថា :

- លោកគ្រូពេទ្យបានចាប់ផ្តើមប្រយុទ្ធជាមួយជនត្រកូលសៃហើយ, សូមលោកនាយក្រុមឆាប់ចេញទៅជួយគាត់ផង ។

- សៃយានទីទះស្មាលោកគ្រូពេទ្យមួយដៃហើយ ។

- លោកគ្រូពេទ្យកាប់ដៃអាវសៃយានទីដាច់ម្ខាងហើយ, តែជនត្រកូលសៃទះគាត់ចំទ្រូងវិញ ។

- លោកគ្រូពេទ្យចេះតែក្អកខ្លះៗ ព្រួសឈាមទៀតផង, បើលោកនាយក្រុមមិនចេញទៅជួយច្បាស់ជាវិវរធំហើយ !

-សៃយានទីហ៊ានពោលសំដីថា ដៃគាត់ចាំងពីរពេចកំទេចក្រុមឈានល្អឲ្យវិនាសសាបសូន្យ, បើលោកនាយមិនចេញទៅ, គេផុតជំរំយើងខ្ទេចជាផេះហើយ ។

ស៊ីផុនយីទ្រាំមិនបាន ក៏ដាច់ចិត្តដើរចេញពីបន្ទប់ ដោយប្រុងប្រៀបសំដីសំរាប់អង្វរគេសុំទោសសៃយានទីជាស្រេច ។ គ្រាន់តែឃើញស៊ីផុនយីភ្លាម, សៃយានទីភ្ញាក់ព្រើតស្រែកសួរ :

- ថ្កុតតពូជ ! ឯងនៅទីនេះទេឬ ?

ចៅហៃស៊ីពេលនោះមានរបួសយ៉ាងដំណំសល់តែដង្ហើមតូចៗ, ដួលដេកស្តូកប្រឡាក់ឈាមពេញខ្លួន ។ ស៊ីផុនយីខ្សោយជាងចៅហៃស៊ីមួយយោជន៍ មានសង្ឃឹមឯណានឹងយកជ័យជំនះបាន ? ជាពិសេសនាយខ្លាចបែកការណ៍ផង ក៏ទទួលពាក្យប្រមាថគាត់ទានពីសៃយានទី ដោយពោលតិចៗ :

-សុំជំរាបសួរលោកគ្រូសៃ !

ត្បិតស៊ីផុនយីគិតថាស៊ីផុនឈានមានឈ្មោះថ្កុតតពូជទេ ។ ហៃសៃយានទីក៏ស្មានថានាយក្រុមរូបនេះជាស៊ីផងបាន ម្ល៉េះហើយគាត់សើចហេសៗពោលចំអក :

- ល្អណាស់, ហ៊ុះ ! អាចង្រៃឯងជានាយក្រុមឈានល្អឬ ?

ពោលដល់នេះគាត់នឹកឃើញរឿងចាស់តាំងពីជួបនាយជំបូងនៅកន្លែងលក់នំ, គាត់គ្រជាក់ខ្លួនស្រប

នឹកបារម្ភម្ដងទៀតវិញដូចកាលគាត់ទើបទទួលផ្លាកសិរីវឌ្ឍិពីកូនស្ងួមដំបូង, ឲ្យតែស៊ីផានឬផ្កាឥតពូជប្រើគាត់ឲ្យធ្វើអ្វី, ទោះការនោះពិបាកយ៉ាងណាក៏គាត់ត្រូវបំពេញខាតតែបានដែរ ។

មកដល់ក្រុមឈានល្អគាត់នឹកថា :

– វីវរហើយតើដាន់ហ្គឹង ! ពៅហាស៊ីមានគំនិតស៊ីរូងជ្រៅណាស់តើ ! អីចឹងបានជាគេឲ្យឆ្កាដាត្រូតេឲ្យដៃធើត ៗ ពិតជាតាប៉ុហ្នឹងដឹងថាយើងបានទទួលផ្លាកបញ្ញាសិរីវឌ្ឍិពីកូនស្ងួមហើយ ! គេខំតាមតេវដល់កុម្ម៉ាដាន ដើម្បីតែងតាំងវាជានាយក្រុមកាយ៉ង ញាក់ខ្សែឲ្យវាបញ្ជាយើងធ្វើការអ្វីមួយបម្រើផលប្រយោជន៍ក្រុមឈានល្អ ៗ ហ៊ឹ ! សែយានខំអើយ ! ឯងធ្លាប់ធ្លាកវាងវៃ, ឥឡូវម្ដេចក៏ម្ល៉េះ ? ខំធ្វើដំណើរមកចូលអន្ទាក់គេដូច្នេះ ? ចាប់ពីថ្ងៃនេះទៅ, ឯងលែងមានសេរីភាពពេញបរិបូណ៌ហើយ !

គិតទៅមនុស្សយើងនឹងថាធ្លាកធំទៅក៏មិនប្រាកដ, ព្រោះមានអ្នកខ្លះខ្លាំងពូកែដល់កំពូលហើយគង់នៅមានចំណុចខ្សោយម្ដងៗ ចាញ់ប្រៀបគេ ឬ ចាញ់សម្ដីគេជាអសារឥតការ ៗ សែយានខំស្ថិតនៅក្នុងករណីនេះឯង ៗ គាត់ស្មានហើយជឿជាក់ថា ពៅហាស៊ីដឹងរឿងផ្លាកសិរីវឌ្ឍ, ស៊ីផុងយីជាផ្កាឥតពូជ ជាកូនស្ងួម, ដែលបានទទួលបញ្ញាសិរីវឌ្ឍគាត់ ម៉្លោះហើយគាត់សញ្ជឹងគិតយូរតែគយ, គិតមុននេះ គាត់ឈរសម្លឹងមុខស៊ីផុងយីក្អឹះៗ រង់ចាំបញ្ជា ព្រមទាំងគិតថា :

–បើគេឲ្យយើងកាប់ដៃទាំងសងខាងចោល, យើងក្លាយជាមនុស្សពិការ ... តើត្រូវធ្វើយ៉ាងម៉េច?

បើគាត់បង់គេចវេះពីផ្កាឥតពូជមិនជាការពិបាកទេ ៗ ប៉ុន្តែបើជាចិត្តធ្វើដូច្នេះមែនឈ្មោះសែយានខំត្រូវលុបបាត់ពីបញ្ជីអ្នកក្លាហាន ព្រោះគាត់បានស្បថស្បែប្រតិបត្តិតាមបញ្ជាអ្នកកាន់ផ្លាំងសិរីវឌ្ឍ ៗ តើថ្ងៃក្រោយពាក្យសម្បថក្លាយទៅជាអ្វី ? តើគាត់ត្រូវរងទុក្ខវេទនាលើសពេលនេះប៉ុន្មានភាគ ?

សែយានខំសម្លឹងមុខស៊ីផុងយីឥតព្រិច, ស៊ីផុងយីកំពុងភ័យផ្អកៗតាមលបសង្កេតទឹកមុខសែយានខំដែលចេះតែប្រែប្រួលចុះឡើងមិនដឹងគាត់ត្រិះរកស្មៀតណាប្រហារខ្លួន ៗ

គេឈរមើលមុខគ្នាមួយសន្ទុះធំដូចពេលវេលាមិនដើរទៅមុខសោះ ៗ សែយានខំអត់ទ្រាំមិនបានទើបស្រែកមួយរំពងថា:

– នែផ្កាឥតពូជ ! យើងបានទទួលផ្លាំងសិរីវឌ្ឍពីដៃឯង យើងមិនគេចវេះទេ, សំដីយើងមាន

តម្លៃដូចហាសពេជ្រ... ឯងត្រូវការប្រើយើងធ្វើអ្វី,បញ្ជាមក ! ទោះមានឧបសគ្គយ៉ាងណាក៏យើងមិនរួញរាដែរ ។

ស៊ីផុងយីទៅជាស្រឡាំងកាំង, តែភ្លាមនោះនាយនឹកឃើញភ្លាម ។ ក្បិតនាយធ្លាប់ឮគេនិយាយពីរឿងឬទ្ធិផ្ទាំងស័ក្តិសិទ្ធិដែរ ត្រូវនឹងនាយមានប្រាជ្ញាឆ្លាតវៃស្រាប់ក៏យល់ថាសែយានទីប្រឡូកនាយជាមួយស៊ីផជានហើយ ។

អីយ៉ា ! នេះជាសំណាង, ជាភ័ព្វព្រេងវាសនាពីជាតិមុនទេតើ ! អម្បាញ់មិញសែយានទីថាទោះពិបាកយ៉ាងណាក៏គាត់មិនរួញរាដែរ ។ ហើ, តាបុំនេះខ្លាំងពូកែប៉ុណ្ណឹងធ្វើការអីមិនសម្រេច ? យើងគិតពីងគាត់ធ្វើអីហ្ន៎ ?

បុរសមេខ្លួចសញ្ជឹងគិត ធ្វើឲ្យសែយានទីពោលបញ្ជាក់ទៀតថា :

– យើងត្រកូលសែធ្លាប់អួតអាងពេញពិភពគុនថាមិនប៉ះពាល់ជនដែលមានផ្ទាំងស័ក្តិសិទ្ធិជាដាច់ខាត, តើឯងនៅញញើតអ្វី ? ផ្គត់គពូជឯងនេះប្រសប់ធ្វើពើណាស់, មើល៍,យុទ្ធសិល្បៈក្តៅឧណ្ហៗឯងជឿនលឿនដល់ថ្នាក់ណាហើយ ?

ស៊ីផុងយីឥតដឹងយុទ្ធសិល្បៈក្តៅឧណ្ហៗជាអ្វីឡើយ ។ នាយគ្រាន់តែសើចខ្ទឹបធ្វើហី ដើម្បីបន្លំភ្នែកសែយានទីប៉ុណ្ណោះព្រមតាំងពិចារណា :

– គ្រោះថ្នាក់យើងធំបំផុតនៅត្រង់ក្នុងកកកនោះឯង ។ បើអាល្វីល្វីមួយនោះទៅបើកកកាយការសម្ងាត់ប្រាប់គេទៅប៉ាយជ័ចាយ, ប៉ាយរ៉ាន់ជានប្តូហ្វឹងរ៉ាន់លីមិននៅស្ងៀមឡើយ, ច្បាស់ជាចុះចាកភ្នំមករករឿងខឹងយើងទៀតហើយ ។ ណ្ហ៎យ ! សំរេចរឿងក្នុងកកកសិនទើបមានផ្លូវរស់ក្នុងពិភពគុនតទៅទៀត ! សំណាងល្អណាស់បានជាតាបុំនេះមកដល់កន្លែងយើង ។ ត្រូវប្រើគាត់បំពេញកិច្ចនេះឲ្យយើងជាដាច់ខាត ! បើគាត់អាចកំចាត់ក្រុមឈានល្អបាន,ក្រុមក្នុងកកក អាចវិនាសសាបសូន្យដោយសារស្នាដៃគាត់ដែរ ។

ស៊ីផុងយីត្រិះរិះថ្លឹងហេតុផលសព្វគ្រប់ទើបសើចស្រស់គបថា :

– លោកគ្រូសែកាន់ពាក្យសច្ចៈទៀងទាត់ណាស់, គួរឲ្យសរសើរមែន ! រឿងដែលខ្ញុំចង់ពឹងពាក់លោកទៅបំពេញជំនួសខ្ញុំនោះ បើលេចឮដល់ត្រចៀកគេ, គេអាចចាត់ទុកជាការមួយគួរស្រៀវស្បើប ប៉ុន្តែចំពោះលោកគ្រូខ្ញុំយល់ថាជាការងាយដូចក្មេងបកចេកស៊ីចឹង ។

សៃយ៉ានទីអរកើតព្រោះសំដីនេះគ្មានន័យចង់ប្រើគាត់កាប់ដៃឬជើងបោះចោលទេ ។ គាត់សួរក្អាម :

– ឯងចង់ឲ្យយើងធ្វើអី ?

– សុំអភ័យទោសចុះ !! ខ្ញុំចង់ឲ្យលោកគ្រូទៅរំលាយក្រុមក្ដុំទឹកកកកុំឲ្យសល់ម្នាក់ណា !

សៃយ៉ានទីភ្ញាក់ព្រញើតនឹកថាក្រុមក្ដុំទឹកកកមានសិស្សខ្លាំងពូកែកប់សិប, មានសមាជិកកប់រយ ហើយជាពិសេសនាយក្រុមប៉ាយជីតាយល្បីឈ្មោះពេញពិភពគុន, អ្នកគ្មានពូកែល្មមៗ មិនហ៊ានទៅក្បែរផង ម្ដេចឡើយថៃ្លឥតពូជនិយាយដូចឆាយម្ល៉េះ ?

ប៉ុន្តែសៃយ៉ានទី មិនចេះខ្លាចមិនចេះញញើតអ្វីទេ, ឡែតមានផ្ដាំងបញ្ញាដែកសំរិទ្ធ ហើយគាត់ត្រូវប្រតិបត្តិតាមជាដាច់ខាត ព្រោះគាត់ធ្លាប់ប្រព្រឹត្តអំពើល្អផង អាក្រក់ផងគ្រប់បែបយ៉ាង, ម្ល៉ោះហើយគាត់ងក់ក្បាលក្អាមពោល :

– បាន ! យើងលាសិនហើយ !

សៃយ៉ានទីបែរខ្លួនប្រុងដើរចេញទៅ, ស៊ីជុនយីស្រែកឃាត់ :

– លោកគ្រូ សុំរង់ចាំបន្តិច ។

–នៅមានការអីទៀតឬ ?

ដ្បិតសៃយ៉ានទីយល់ថា ថៃ្លឥតពូជប្រើគាត់ឲ្យកំចាត់ក្រុមក្ដុំទឹកកក តាមសេចក្ដីស្នើរបស់ពៅហាស៊ី, គាត់មិនយល់ថាក្រុមឈានល្អមានគំនុំអីជាមួយក្រុមក្ដុំទឹកកកទេ, ប៉ុន្តែគាត់មិនហ៊ានសួរ ខ្លាចពៅហាស៊ីប្រើកលល្បិចបែបណាទៀត, ជាពិសេសគាត់ចង់ទៅបំពេញកិច្ចនោះឲ្យបានរហ័សនឹងអាលទំនេរគិតគូរ ទំនេរខួរក្បាលបន្តិចអស់ខ្វាយខ្វល់ពីរឿងពាក្យសំបថ ។

ស៊ីជុនយីពោល:

– លោកគ្រូសៃ, ខ្ញុំចង់ទៅជាមួយលោកដើម្បីមើលស្នាដៃលោករំលាយក្រុមក្ដុំទឹកកកបានផ្ទាល់ភ្នែក ។

*

* *

## វគ្គទី ៣៨

## បញ្ហារបស់ក្ងួនស្ទូម

តាំងពីក្រុមឈានល្បួចាប់ស៊ីផុនយីបានលើកក្រោយនេះ គេប្រយ័ត្នប្រយែងសម្ងៀមណាស់ខ្លាចនាយល្បួចគេបាត់ទៀត ។ ស៊ីផុនយីព្រួយចិត្តដូចខ្លាជាប់ទ្រុងតែងពិគ្រោះជាមួយទីនតុនថា តោះ បើយ៉ាងណាក៏មិនទៅកោះឡុនមុជទួសស៊ីផធានដែរ ។ ម៉្យាងទៀតបង់រត់ចេញពីជំរំឈានល្បួឃើញថាមិនងាយស្រួលឡើយ, ត្រូវចេញដំណើរទៅកោះឡុនមុ ហើយត្រៀតឱកាសគេបន្ធូនទើបមានផ្លូវខ្លះ ។

ក្រុមឈានល្បួគោរពកោតខ្លាចនាយក្រុមតែសំបកក្រៅទេ, គេមិនហ៊ានធ្វើអ្វីឲ្យនាយឃើសចិត្តមែន, តែកល់យប់កល់ថ្ងៃគេចាត់ចែងឃាមល្បាតម៉ត់ចត់ណាស់ មិនឲ្យនាយទៅណាឡើយ, មានតែទីនតុនទើបចេញចូលជំរំបានតាមចិត្ត ។

ស៊ីផុនយីមានពុតត្បុតក៏ដូចមានប្រាជ្ញាធ្លាតវៃនាយនឹកឃើញថានេះជាឱកាសល្អហើយ ។ ដំណើរទៅភ្នំទឹកកកអាចផ្ដល់ផលប្រយោជន៍ពីរយ៉ាងឲ្យយើង គឺមួយអស់ភ័យបារម្ភពីរឿងក្រុមភ្នំទឹកកក, ពីរយើងអាចចេញផុតពីក្រុមឈានល្បួរត់រកកន្លែងថ្មី ។

សៃយានទឺយល់ថាសំបថគាត់កំពុងតែរឿងតែមួយមែន ឯស៊ីផុនយី សុំទៅមើលការកំចាត់ក្រុមភ្នំទឹកកកគាត់មិនអាចបដិសេធទេ, ម៉្លោះហើយគាត់ងក់ក្បាល :

– បាន, ឯងទៅជាមួយចុះ ។

សមាជិកក្រុមឈានល្បួបែរមើលមុខតៃហៃស៊ុំ ដែលចាំសេចក្ដីសម្រេចចិត្ត, តែស៊ីផុនយីពោលមុន:

– បើខ្ញុំសុខចិត្តទៅកោះឡុនមុជន្ទួសបងប្អូនហើយ, សុំជឿខ្ញុំចុះ, ដល់ពេលសន្យាខ្ញុំមិនឲ្យបងប្អូនពិបាកចិត្តទេ ។

តៃហៃស៊ុំមានប្ញូសធ្ងន់ស្ទើរស្លាប់ ឥតបានស្មានថាសៃយានទឺព្រមស្ដាប់បញ្ជានាយក្រុមស៊ុំ ដោយងាយៗយ៉ាងនេះទេ ។ គាត់មិនអាចកាំងបានក៏ពោលខ្សាវៗ :

– សូមលោក .. នាយក្រុម... ទៅ.. ឲ្យបានសុខ, ខ្ញុំបាទ ខេះៗ...ខេះ ! មិនបានជូនដំណើរទេ ។

ស៊ីផុនយីអរគុណសំដែងគារវកិច្ច ហើយចេញដំណើរជាមួយសៃយានទឺទៅ ។

លុះផុតពេលជំរើចសៃយានទីសើចចំអក :

– ខ្ញុំដឹងថាឯងប្រសប់ធ្វើពើណាស់ហ្ន៎ ! គ្រប់ពេលសៃយើងមានវិក័យណាស់មិនមែនខ្លាចទេ, យើងថាឯងជាសិស្សទ័ពមិនហួសបួន, សម្រេចសម្រួលឯងធ្វើនាយក្រុមឈានល្អសោះ ! ហ៊ុះ ! ហាស១ . . .

សៃយានទីអស់ខ្វាចស៊ីផុនយីហើយ ព្រោះគាត់ទទួលបញ្ជាទៅបំពេញសំណូមពរតាមពាក្យសំបថ ៗ គាត់មិនហ៊ានយារដៃវាយតប់ដល់រូបកាយនាយប៉ុណ្ណោះ គ្រាន់ពាក្យសំដីគាត់ពេចពោលញុះញង់ ឬគ្រិះគិះជៀលតាមតែនឹកឃើញ ៗ

ស៊ីផុនយីនៅតែបន្ទំសើចញឹមៗ ពោលយ៉ាងគោរពថា:

– សូមលោកមេត្តាអភ័យទោស !

ទឹងតុងចេញចូល ៗ ស្រាប់តែមកជួបគេដៃរកវៀមដំណើរទៅក្មួយក្រុម ៗ ស៊ីផុនយីគាំងលើកម្ទាំងសៃយានទីហើយ តែនាយគ្នាប់គោគខ្វាចប៉ាយជីបាយចិនប៉ាយរាំងជាមតាំងពីតូចក៏ទៅក៏យបារម្ភវេល, និយាយបញ្ចុះបញ្ចូលឲ្យសៃយានទីលួចសម្លាប់សិស្សក្នុងក្រុមបួនមួយដោយសម្ងាត់ ៗ សេចក្ដីស្នើនេះស្របនឹងចិត្តសៃយានទីប៉ាប់តែម្ដង ៗ ម្ល៉ោះហើយអ្នកទាំងបីនាំគ្នាឡើងក្នុងក្រុមតាមស៊ីផុនយី ព្រោះបុរសនេះស្គាល់គន្លងក្រៀតច្បាស់ណាស់ជាងគេ ៗ ទៅតាមផ្លូវគេបានសម្លាប់សិស្សក្នុងក្រុមអស់បួននាក់ ៗ សៃយានទីស្ដាប់របៀបវែកគ្នាយល់ថាមានវិបត្តិផ្សេង ហើយដឹងទៀតថា ប្ដីប្រពន្ធស៊ីឈីងជាប់ឃុំទៀត ៗ ស៊ីផុនយីជាក្បួនលខ្ទប ហើយការ ការពារមែន , នាយស្រឡាញ់ឪពុកម្ដាយណាស់ តែមិនហ៊ានហៅរកសៃយានទីឲ្យជួយរំដោះ ក៏នាំគាត់ទៅដល់ទីឃុំឃាំង ៗ

សៃយានទីសម្លាប់អ្នកយាមអស់ប៉ុន្មាននាក់ទៀតទើបជួយស៊ីឈីងនិងវុនយូចេញពីទីនោះបាន ៗ គ្មានពេលដំណាលគ្នា, យាយស៊ី, ប៉ាយរាំងជានិងស៊ីផាន កំពុងនិយាយរួមប៉ាយជីបាយគួរបន្ទប់មួយទៀត ៗ គេមិនទាន់ដឹងហេតុការណ៍នៅខាងក្រៅទេ ៗ សៃយានទីចង់សម្លាប់ម្ដងមួយៗតាមតែប្រទះឃើញដើម្បីឲ្យក្រុមក្នុងកកវិនាសរាបសូន្យខាប់ៗ តែស៊ីឈីងនិងវុនយូឃាត់ពេកហើយស៊ីឈីងពោលចំអក

– យើងជាអ្នកក្លាហានគួរប្រកួតប្រជែងនឹងលោកតានាយក្រុមឲ្យឃើញសាច់ស៊ន, បើម្ចាស់

ផ្ទុះមិនទាន់ចេញមកផង, យើងសម្លាប់កូនគេអស់ទៅ, ថ្ងៃក្រោយលេចឮដល់អ្នកកុម្មុនិយមខ្លួនទៅ យើងយកមុខទៅទុកឯណា ? ពិតជាគេថ្កោលទោសថាយើងហ៊ានសម្លុតតែកូនក្មេងហើយ !

សៃយានខឹតបទាំងសោះកក្រោះថា:

– បើគង់តែសម្លាប់ឲ្យផុតពូជដដែល , យើងសម្លាប់ក្មេងមុនឬចាស់មុនក៏ដូចគ្នាដែរ ។

មិនយូរប៉ុន្មានយាយស៊ីនិងប៉ាយវ៉ាន់ផានចេញមកដល់ ។ លុះនិយាយមិនចុះសម្រុងគ្នា គេចាប់ផ្ដើមប្រយុទ្ធគ្នាភ្លាម ដោយប៉ាយវ៉ាន់ផានចូលមុន, តែប៉ាយវ៉ាន់ផានមិនមែនជាគូប្រយុទ្ធជាមួយសៃយានខឹទេ, មិនយូរប៉ុន្មានម្ចាស់ក្ដីម៉ានវាយគាត់ទាល់ច្រករកតែវិញលែងកើត ។ ឈឹងជីសេ និងឈីជីមានឮសៃយានខឹប្រកាសថា សម្លាប់សិស្សក្តិកកកឲ្យផុតពូជ ក៏បំភ្លេចរឿងរ៉ាវទាំងប៉ាយវ៉ាន់ផានអស់ទៅ ។ គេដកដាវស្ទុះចូលព្រមគ្នា រួមកម្លាំងជាមួយបងទប់ទល់នឹងកម្លាំងយុទ្ធសិល្បៈដៃខ្មៅរបស់សៃយានខឹ ។ បីនាក់ប្រួតដៃគ្នានៅមិនឈ្នះទៀត ។

ពេលដែលស៊ីផានចេញមកនោះ, យាយស៊ីប្រឹងស្ទុះចូលជួយតែសៃយានខឹភ្ញាក់ផ្អើលនឹងសម្រែកស៊ីផានពេកត្រឡប់ស្ថានការណ៍ឲ្យប្រែប្រួលស្រឡះវិញមួយរំពេច ។

ចំណែកស៊ីផុងយើងនិងចិងតុងស្មានក្នុងចិត្តតាំងពីនៅទីតាំងក្រុមឈានល្បម៉េះថា ប៉ាយជីតាយកាចផងចិត្តខ្លាំងផង, ឃើញមុខមាណពគាលណាម្នាក់ជាសម្លាប់ចោលឥតមើលមុខទេ, ឥតទុកពេលឲ្យដោះសារទេ ។ ពេលនេះស្រាប់តែឃើញស៊ីផានដើរចូលមកប្រាស់សន្ធារ, គេភ្ញាក់ផ្អើលនិងជឿងឆ្ងល់ជាខ្លាំង ។

(នៅមានត)

ចំកល់ទុកតាមលេខ ៨០១ ចុះថ្ងៃទី ១៧ ៦ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ក្បាល